# មជ្ឈមណ្ឌលឯកសារកម្ពុជា

# គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

# (១៩៧៥–១៩៧៩)

## ការចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
## វេទិកាសាធារណៈស្តីពីការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
## រវាងគ្រូ សិស្ស និងឪពុកម្តាយ

## ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
## ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០



***សិស្សចូលរួមក្នុងការធ្វើវេទិការសាធារណៈស្តីពីការអប់រំ***

មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាផ្លូវការមួយ ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៨ ។ ជាផ្នែកមួយនៅក្នុងគម្រោងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)” ចំនួន៣០០.០០០ច្បាប់ ដើម្បីចែកដល់អនុវិទ្យាល័យ និងវិទ្យាល័យចំនួនជាង ១.៥០០កន្លែងក្នុងទូទាំងប្រទេសកម្ពុជា ។ បន្ថែមទៅលើការចែកចាយសៀវភៅប្រវត្តិសាស្ត្រនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានបើកវគ្គបណ្តុះបណ្តាលគ្រូឯកទេសប្រវត្តិវិទ្យា អក្សរ

សាស្ត្រខ្មែរ និងសីលធម៌-ពលរដ្ឋ ពីគរុកោសល្យនិងវិធីសាស្ត្រក្នុងការបង្រៀន ដើម្បីឲ្យគាត់មានជំនាញក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលារៀន ។ រហូតមកដល់បច្ចុប្បន្ននេះ គ្រូឯកទេសប្រវត្តិវិទ្យាចំនួនជាង១.០០០នាក់មកពីខេត្តចំនួន១៨ បានទទួលការបណ្តុះបណ្តាលរួចហើយ ។ នៅបំណាច់ឆ្នាំ២០១១នេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជននិងកីឡា នឹងធ្វើការបើកវគ្គបណ្តុះបណ្តាលរបៀបដូចគ្នានេះដល់គ្រូចំនួនជាង៣.២០០នាក់បន្ថែមទៀត ។

ដូចមានជាភស្តុតាងស្រាប់នៅក្នុងវគ្គបណ្តុះបណ្តាលគ្រូ ដែលបានប្រារព្ធធ្វើឡើងនៅក្នុងខែធ្នូឆ្នាំ២០០៩ នាពេលកន្លងមក ចំណេះដឹងរបស់គាត់ស្តីអំពីរបបខ្មែរក្រហម គឺដឹងត្រឹមតែបទពិសោធន៍ផ្ទាល់ខ្លួន បទពិសោធន៍របស់សាច់ញាតិ និងមិត្តភក្ត្រប៉ុណ្ណោះ ។ នៅចុងបញ្ចប់វគ្គបណ្តុះបណ្តាល សិក្ខាកាមម្នាក់មកពីខេត្តកណ្តាលបានថ្លែងអំណរគុណដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងគ្រូឧទ្ទេសថ្នាក់ជាតិ ដែលបានបង្រៀនគាត់អំពីប្រវត្តិសាស្ត្រខ្លួនឯង ។ គាត់បាននិយាយថា *“វគ្គបណ្តុះបណ្តាលនេះ បានជួយខ្ញុំឲ្យមានការស្វែងយល់កាន់តែច្រើនថែមទៀត ។ ឧទាហរណ៍ ខ្ញុំបានដឹងតែមន្ទីរសន្តិសុខតែពីរបីប៉ុណ្ណោះ ។ ដោយសារតែឯកសារនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានដឹងថាមានមន្ទីរសន្តិសុខចំនួនជិត២០០កន្លែង ក្នុងអំឡុងពេលនៃរបបខ្មែរក្រហម”* ។ ការគិតនេះមិនត្រឹមតែកើតមានចំពោះសិក្ខាកាមមកពីខេត្តកណ្តាលប៉ុណ្ណោះទេ ប៉ុន្តែហាក់ដូចជាកើតមានឡើងចំពោះសិក្ខាកាមនានាដែលមកពីគ្រប់កន្លែងទាំងអស់ ។ ឧទាហរណ៍ សិក្ខាកាមស្ត្រីម្នាក់មកពីខេត្តបាត់ដំបងបានថ្លែងថា គាត់បានដឹងតិចតួចណាស់អំពីរបបខ្មែរក្រហម ប៉ុន្តែឥឡូវគាត់បាននិយាយថា *“ខ្ញុំដឹងច្រើនណាស់អំពីខ្មែរក្រហម នយោបាយ និងមនោគមន៍វិជ្ជារបស់ខ្មែរក្រហម ។ ខ្ញុំមានអាយុជាង២០ឆ្នាំហើយ គឺប្រហែលជា២៤ឆ្នាំ នៅពេលដែលខ្មែរក្រហមកាន់កាប់អំណាច ។ ឥឡូវនេះ ខ្ញុំអាចចែករំលែករឿងរ៉ាវជាមួយអ្នកទាំងអស់គ្នានៅវគ្គបណ្តុះបណ្តាលនេះបាន”* ។

ដោយសារតែការយល់ឃើញបែបនេះ ទើបមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានដឹងថាភាពសោកសៅទាំងនេះកើតមាននៅក្នុងអារម្មណ៍របស់ប្រជាជនកម្ពុជាភាគច្រើននិងបានព្យាយាមក្នុងការបំពេញបន្ថែមនូវស្ថានភាពបែបនេះ ។ ហេតុដូច្នេះហើយ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រារព្ធធ្វើវេទិកាសាធារណៈស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅខែសីហា ឆ្នាំ២០១០ ដើម្បីលើកកម្ពស់ដល់ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម បង្កើនការផ្សះផ្សា និងការពារឧក្រិដ្ឋកម្មអមនុស្សធម៌ផ្សេងៗដែលបានកើតមាននៅក្នុងប្រទេសកម្ពុជា ។ គោលបំណងនៃគម្រោងស្តីពីការអប់រំក្រៅប្រព័ន្ធមានដូចខាងក្រោម៖

១) ផ្តល់ការអប់រំក្រៅប្រព័ន្ធស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅដល់សហគមន៍កម្ពុជា ដែលផ្តោតសំខាន់ជាចម្បងទៅលើប្រជាជនដែលរស់នៅទីជនបទឆ្ងាយៗ និងមានលទ្ធភាពតិចតួចបំផុតក្នុងការទទួលបានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងឯកសារផ្សេងៗទៀតស្តីអំពីរបបខ្មែរក្រហម ។

២) ផ្តល់ឱកាសដល់អ្នកភូមិដែលជាជនរងគ្រោះ និងជនដៃដល់ ឲ្យបង្កើតការពិភាក្សា និងសហការជាមួយលោកគ្រូអ្នកគ្រូ ក្នុងការបង្រៀនដល់កូនចៅរបស់ខ្លួនអំពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។

៣) វេទិកានេះ មិនត្រូវបានបង្កើតឡើងដើម្បីឲ្យអ្នកភូមិបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់ដល់កូនៗរបស់គាត់ឡើយ ប៉ុន្តែវេទិកានេះបាននាំយកការយល់ដឹងពីបរិបទប្រវត្តិសាស្ត្រដ៏ធំទូលាយមួយដល់សហគមន៍តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្លួនធ្លាប់ឆ្លងកាត់របបខ្មែរក្រហមទៅប្រាប់កូនៗ ឬក្មេងជំនាន់ក្រោយ ។

ដូចមានជាភស្តុតាងស្រាប់ក្នុងការចូលរួមបញ្ចេញមតិ និងសំណួររបស់អ្នកចូលរួមនៅក្នុងពេលប្រារព្ធធ្វើវេទិកាសាធារណៈនៅខេត្តកំពង់ស្ពឺនេះ មានប្រជាជន និងលោកគ្រូអ្នកគ្រូមួយចំនួនដែលធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូស្តីពីការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម គឺមានចំណេះដឹងតិចតួចណាស់អំពីបរិបទសង្គមនយោបាយដ៏ធំទូលាយ និងរឿងរ៉ាវដែលជាប់ទាក់ទងនឹងរបបខ្មែរក្រហម ។ ឧទាហរណ៍ អ្នករស់រានពីរបបខ្មែរក្រហមម្នាក់អាចចងចាំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម និងរឿងរ៉ាវខ្លះដែលបានកើតឡើងមកលើខ្លួនគាត់ ប៉ុន្តែគាត់មិនអាចចាំបានពីរឿងរ៉ាវធំៗជាច្រើនទៀត ឬរចនាសម្ព័ន្ធច្បាប់របស់ខ្មែរក្រហមឡើយ ។ លើសពីនេះទៀត អ្នកចូលរួមខ្លះបានសួរសំណួរទូទៅដូចជា «ហេតុអ្វីបានជាខ្មែរក្រហមកើតមានឡើង? តើនរណាជាអ្នកកាន់អំណាចនៅក្នុងរបបខ្មែរក្រហម?» ដែលសំណួរទាំងនោះបានបង្ហាញពីការយល់ដឹងតិចតួចរបស់អ្នករស់រានពីរបបខ្មែរក្រហម ។ អ្នកចូលរួមដទៃទៀតបានសួរសំណួរដែលទូលំទូលាយនិងពិបាកផ្តល់ចម្លើយ ដូចជា « ហេតុអ្វីបានជាប៉ុល ពត សម្លាប់មនុស្ស ប្រសិនបើគាត់មិនចង់ឲ្យប្រជាជនមានការលំបាក? ឬ ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់បញ្ញវន្ត នៅពេលដែលមេដឹកនាំខ្មែរក្រហមមួយចំនួនសុទ្ធតែជាមនុស្សមានការអប់រំ?» ។ នៅក្នុងន័យនេះការសិក្សាស្តីពីអំពើប្រវត្តិសាស្ត្រខ្មែរក្រហម មិនត្រឹមតែដាក់បញ្ចូលនៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេ ប៉ុន្តែការសិក្សានេះគួរតែពង្រីកបន្ថែមទៅកាន់សាលារៀនផ្សេងៗទៀត និងទៅដល់សហគមន៍ឲ្យបានទូលំទូលាយ ។ សម្រាប់ការអប់រំដែលប្រកបទៅដោយប្រសិទ្ធភាព គឺតម្រូវឲ្យមានការចូលរួមពីគ្រូបង្រៀន សិស្សានុសិស្ស ឪពុកម្តាយមន្ត្រីរាជការ និងមនុស្សចាស់ ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងភាពអមនុស្សធ៌មទាំងឡាយ ដែលដំណើរការនេះត្រូវតែធ្វើឡើងចាប់ពីថ្នាក់មូលដ្ឋានឡើងទៅ ។

វេទិកាសាធារណៈលើកដំបូង បានប្រារព្ធធ្វើឡើងនៅភូមិអន្លង់ជ្រៃ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ហើយការអធិប្បាយពីដំណើរការនេះ គឺមានរៀបរាប់ដូចខាងក្រោមៈ

## លក្ខណៈភូមិសាស្ត្រ

វេទិកាសាធារណៈស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យលើកដំបូង ត្រូវធ្វើឡើងនៅក្នុងវិទ្យាល័យ ហ៊ុនសែន អន្លង់ជ្រៃ ស្ថិតក្នុងភូមិអន្លង់ជ្រៃ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ វិទ្យាល័យនេះមានទីតាំងស្ថិតនៅប្រមាណ៥២គីឡូម៉ែត្រពីទីរួមខេត្តកំពង់ស្ពឺ ។ ផ្លូវឆ្ពោះទៅកាន់ទីតាំងនេះ មានសភាពងាយស្រួលច្រើនដោយសារតែមានការជួសជុលច្រើនដងដើម្បីជួយសម្រួលដល់ការធ្វើដំណើរនិងដឹកជញ្ជូន ។ វិទ្យាល័យនេះត្រូវបានកសាងឡើងនៅឆ្នាំ១៩៨១លើទំហំដី៧ហិកតា ដែលកាលនោះគឺជា “អនុវិទ្យាល័យថ្ពង” ។ នៅឆ្នាំ២០០៧ សាលានេះបានបង្កើតទៅជាវិទ្យាល័យវិញ ។ វិទ្យាល័យនេះ មានអគារចំនួនប្រាំខ្នងរួមទាំងអគារការិយាល័យរដ្ឋបាលមួយផង ។ មានថ្នាក់រៀនទាំងអស់ចំនួន២៨បន្ទប់ ដែលអាចដាក់ឲ្យសិស្សចូលរៀនបានចំនួន៧៤៥នាក់ គ្រូចំនួន២៥នាក់ រួមទាំងបុគ្គលិករដ្ឋបាល និងនាយកសាលាផង ។ ក្នុងចំណោមគ្រូដែលបង្រៀននៅក្នុងវិទ្យាល័យនេះទាំងអស់ មានគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាចំនួន៤នាក់ គ្រូអក្សរសាស្ត្រខ្មែរចំនួន៣នាក់ និងគ្រូសីលធ៌មពលរដ្ឋចំនួន៣នាក់ ដែលគ្រូទាំងនោះមិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា នោះទេ ។ វិទ្យាល័យនេះ មានបង្រៀនសិស្សចាប់ពីថ្នាក់ទី៧ដល់ទី១២ ។ ដោយសារតែគ្រូមានចំនួនតិច ទើបមានគ្រូខ្លះបង្រៀនមុខវិជ្ជាពីរឬបីក្នុងម្នាក់ឯង ។

ដោយសារតែស្ថិតនៅទីជនបទដាច់ស្រយាល ទើបវិទ្យាល័យនេះជួបប្រទះនូវឧបសគ្គមួយចំនួនដែលបង្កឲ្យមានការប៉ះពាល់ដល់ការបង្កើនគុណភាពនៃការអប់រំ ។ ដីរាប់ពាន់ហិកតាបានក្លាយទៅជាដីសម្បទានសម្រាប់គ្រូមហ៊ុនឯកជន ។ សិស្សជាច្រើនបានគេចវេសសាលារៀន ហើយបានទៅធ្វើការឲ្យក្រុមហ៊ុនដើម្បីរកប្រាក់ចំណូលបន្ថែមសម្រាប់ចិញ្ចឹមគ្រួសាររបស់ខ្លួន ។ ឪពុកម្តាយខ្លះបានជម្រុញឲ្យកូនៗបោះបង់ចោលការសិក្សាហើយងាកមកជួយរកស៊ីគ្រួសារវិញ ដោយគាត់យល់ឃើញថា ការសិក្សាគឺមិនសំខាន់ឡើយនិងបានចំណាយពេលវេលាច្រើនឥតប្រយោជន៍សម្រាប់កូនគាត់ដែលត្រូវរៀន ហើយនៅទីបញ្ចប់កូនៗរបស់គាត់នៅតែធ្វើស្រែដដែល ។ គ្រូបង្រៀនដែលទើបនឹងចូលមកបង្រៀនថ្មីគឺមិនអាចទ្រាំទ្រនឹងស្ថានភាពរស់នៅទីនេះបាន ហើយបានផ្លាស់ប្តូរទៅកាន់កន្លែងផ្សេងបន្ទាប់ពីគេបានបំពេញក្របខណ្ឌរយៈពីរឆ្នាំរួចមក ដោយបន្សល់ទុកតែគ្រូដែលមានសមត្ថភាពនិងបទពិសោធន៍តិចតួច ។

## ជួបប្រជុំជាមួយនាយកវិទ្យាល័យ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបណ្តុះបណ្តាលគ្រូថ្នាក់ខេត្តចំនួន១៨០នាក់ មកពីគ្រប់ស្រុកក្នុងទូទាំងប្រទេសកម្ពុជា ។ ដូច្នេះរាល់ការធ្វើវេទិកាសាធារណៈម្តងៗ យើងបានស្នើសុំឲ្យគ្រូថ្នាក់ខេត្តធ្វើការទាក់ទងជាមួយនឹងអាជ្ញាធរមូលដ្ឋានដើម្បីធ្វើវេទិកាសាធារណៈនេះ ។ សមាជិកគ្រូមសម្រាប់គម្រោងនេះរួមមាន កញ្ញា លី សុខចំរើន លោក ឌី ខាំបូលី លោក ផេង ពង្សរ៉ាស៊ី

លោក វ៉ាន់ថាន់ ពៅដារ៉ា និង លោក ប្រាក់ កែវដារ៉ា បានធ្វើដំណើរទៅកាន់ទីតាំងធ្វើវេទិកាមួយថ្ងៃមុន ដើម្បីរៀបចំទីកន្លែង និងឧបករណ៍សម្លេង ក៏ដូចជាធ្វើការពិភាក្សាជាមួយនឹងមន្ត្រីពាក់ព័ន្ធ។ លោកគ្រូ ឃឹម វ៉ន គឺជាគ្រូបង្គោលថ្នាក់ខេត្តមកពីស្រុកថ្ពង គឺជាអ្នកផ្តល់ដំណឹងទៅកាន់មន្ត្រីអប់រំស្រុក និងលោកនាយកវិទ្យាល័យ ព្រមទាំងបានអញ្ជើញលោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងឪពុកម្តាយរបស់សិស្ស ស្តីពីការចុះមកធ្វើវេទិកាសាធារណៈលើកនេះ។ លោកគ្រូ ឃឹម វ៉ន បានជួយដល់ក្រុមការងារច្រើនណាស់ និងបានជួយដល់ការកាត់បន្ថយការចំណាយថវិកា និងពេលវេលាដែលមិនចាំបាច់សម្រាប់ការរៀបចំធ្វើវេទិកាសាធារណៈនេះ។

នៅថ្ងៃទី២២ ខែសីហា សមាជិកក្រុមបានជួបពិភាក្សាពីដំណើរការការងារសម្រាប់ថ្ងៃស្អែក ជាមួយ លោក មាស ធន នាយកវិទ្យាល័យហ៊ុនសែនអន្លង់ជ្រៃ និងលោក ឃឹម វ៉ន។ លោក មាស ធន បានបញ្ជាក់ថា ខែសីហា គឺជាពេលវិស្សមកាលរបស់សិស្ស ដូច្នេះមានតែសិស្សដែលមករៀនគួរបន្ថែមប៉ុណ្ណោះ ដែលអាចចូលរួមក្នុងវេទិកានេះបាន។ លោកនាយកក៏បានអញ្ជើញអ្នកភូមិមួយចំនួនដែលរស់នៅក្បែរៗវិទ្យាល័យ ប៉ុន្តែគាត់បានគិតទុកមុនថា មានតែប្រជាជនភាគតិចប៉ុណ្ណោះដែលអាចមកចូលរួមក្នុងវេទិកានេះបាន ពីព្រោះរដូវនេះជារដូវវស្សា ដែលអ្នកភូមិភាគច្រើនបានយកឱកាសនេះទៅភ្ជួរ និងស្ទូង។ ម្យ៉ាងទៀត រដូវនេះក៏ជារដូវបុណ្យឆេងម៉េងរបស់ជនជាតិចិនផង ដែលជាហេតុធ្វើឲ្យប្រជាជនមួយចំនួនរវល់នឹងការរៀបចំផ្ទះសម្បែង និងសែនព្រេន។

## ពិធីបើកកម្មវិធី

កម្មវិធីពេលព្រឹកបានចាប់ផ្តើមឡើងដោយការប្រកាសបើកកម្មវិធី និងការណែនាំរបស់លោក ផេង ពង្សរ៉ាស៊ី ពីកម្មវិធីសម្រាប់ថ្ងៃនេះ ដែលចាប់ផ្តើមដោយមានការរៀបរាប់យ៉ាងសង្ខេបពីវត្ថុបំណងនៃការធ្វើវេទិកាសាធារណៈស្តីពីការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យរបស់លោក ឌី ខាំបូលី អ្នកនិពន្ធសៀវភៅប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ និងមតិផ្តាំផ្ញើរបស់តំណាងមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាស្រុកថ្ពង។ បូលី បានបញ្ជាក់ពីកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្កើតកម្មវិធីចែកចាយសៀវភៅប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ និងការបណ្តុះបណ្តាលគ្រូ ដែលជាផ្នែកមួយនៃគម្រោងស្តីពីការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ។ បូលី ក៏បានរៀបរាប់ពីសារៈសំខាន់ និងគោលបំណងនៃការធ្វើវេទិកាសាធារណៈស្តីពីការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យថា ជាការសិក្សាពីការបង្រៀនពីប្រវត្តិសាស្រ្តខ្មែរក្រហមក្រៅផ្លូវការ។ បូលី បានបន្តថា វាមានសារៈសំខាន់ណាស់សម្រាប់លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងអ្នកភូមិ

ដែលមានឱកាសមកអង្គុយនៅក្នុងបន្ទប់តែមួយ និងអាចទទួលបាននូវការសិក្សាពីរបបខ្មែរក្រហម ។ សកម្មភាពនេះនឹងអនុញ្ញាតិឲ្យអ្នកចូលរួមទាំងអស់ ស្វែងយល់ពីសារៈសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យក្នុងពេលតែមួយ ។ ការសហការរវាងក្មេងជំនាន់ក្រោយ និងមនុស្សវ័យចំណាស់ដែលជាសាក្សីផ្ទាល់នៃអំពើព្រៃផ្សៃត្រូវតែទទួលបានការលើកទឹកចិត្ត ។ គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល ដើម្បីធានាថា កិច្ចពិភាក្សាគឺកើតមានឡើងនៅក្នុងគ្រួសារ និងសហមគមន៍ ជាទ្រង់ទ្រាយធំ និងបញ្ជាក់ថាសិស្សក៏ជាផ្នែកមួយនៅក្នុងដំណើរការនេះដែរ ដើម្បីឆ្ពោះទៅរកការព្យាបាលរបួសផ្លូវចិត្ត និងការផ្សះផ្សារជាតិ ។

អ្នកចូលរួមនៅក្នុងវេទិកានេះរួមមាន សិស្សានុសិស្សដែលរៀនពីថ្នាក់ទី១០ដល់១២ចំនួន៨៥នាក់ អ្នកភូមិចំនួន៦នាក់ និងគ្រូបង្រៀនចំនួ២នាក់ ។ ដោយសារតែវេទិកានេះត្រូវបានធ្វើឡើងក្នុងអំឡុងពេលវិស្សមកាល ទើបសិស្សានុសិស្សទាំងអស់បានស្លៀកពាក់ខោអាវធម្មតា ។ អ្នកទាំងនោះមកចូលរួមដោយមិនមានកាន់ប៊ិច និងក្រដាសមកជាមួយទេ គឺគ្រាន់តែមកចូលរួមធម្មតាប៉ុណ្ណោះ ។ នៅពេលដែលសួរសំណួរថា តើធ្លាប់បានរៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀនពីមុនមកទេ? សិស្សខ្លះបាននិយាយថាបានរៀនតិចតួចដែរ ។ ដោយស្តាប់ឮថា ប្រវត្តិសាស្ត្រខ្មែរក្រហមបានចេញក្នុងពេលប្រឡងបាក់ឌុបចំនួនពីរលើកកន្លងមកហើយគឺនៅឆ្នាំ២០០៩ និង២០១០ និងបានចេញក្នុងពេលប្រឡងឆមាសនាពេលកន្លងមកដែរនោះ សិស្សទាំងអស់ហាក់មានការចាប់អារម្មណ៍នូវអ្វីដែលក្រុមការងារយើងកំពុងតែផ្តល់ឲ្យនៅក្នុងពេលធ្វើវេទិកាលើកនេះ ហើយបានចាប់ផ្តើមចែករំលែកក្រដាស ប៊ិច និង ខ្មៅដៃ ដើម្បីកត់ត្រា ។

## សកម្មភាពនៅក្នុងវេទិកា

### ១.*ការធ្វើបទបង្ហាញជំពូកទី៨ៈ ប្រព័ន្ធសន្តិសុខ ដោយលោក ផេង ពង្សរ៉ាស៊ី*

រ៉ាស៊ី បានធ្វើបទបង្ហាញដោយចាប់ផ្តើមពីការសួរពីអត្ថន័យនៃពាក្យ "សន្តិសុខ" និងបានសួរសិស្សពីការឡើងកាន់អំណាចនិងការដួលរំលំរបស់ខ្មែរក្រហម ។ សិស្សម្នាក់បានក្រោកឈរឡើងហើយនិយាយថា "របបខ្មែរក្រហមបានកើតឡើងក្នុងចន្លោះថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៧ មករា ១៩៧៩" ។ បន្ទាប់មក រ៉ាស៊ី បានបន្តពន្យល់ពីប្រព័ន្ធសន្តិសុខទាំងប្រាំថ្នាក់ រួមមានមន្ទីរសន្តិសុខថ្នាក់មជ្ឈិម "មន្ទីរស-២១" មន្ទីរសន្តិសុខថ្នាក់ភូមិភាគ មន្ទីរសន្តិសុខថ្នាក់តំបន់ និងមន្ទីរសន្តិសុខថ្នាក់ស្រុកនិងថ្នាក់ឃុំ ។ គាត់បានពន្យល់ពីប្រភេទអ្នកទោសដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួន ។ អ្នកទោសភាគច្រើនដែលជាប់នៅក្នុងមន្ទីរសន្តិសុខមជ្ឈិម

គឺជាអ្នកទោសនយោបាយដែលជាកម្មាភិបាលខ្មែរក្រហម ។ ចំណែកអ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខថ្នាក់ក្រោមៗ គឺមានរាប់បញ្ចូលទាំងអតីតអ្នករដ្ឋការចាស់ និងមន្ត្រីយោធានៃរបប លន់ នល់ និង របបសីហនុ ។ វ៉ាស៊ី បានលើកឧទាហរណ៍ពីរបៀបដែលខ្មែរក្រហមកត់សម្គាល់អ្នកដែលជាអតីតមន្ត្រីរដ្ឋការចាស់ថា មន្ត្រីយោធានៃរបប លន់ នល់ គួរតែមកចុះឈ្មោះនៅក្នុងបញ្ជីពិសេសមួយដើម្បីត្រៀមខ្លួនទទួលតួនាទីដូចដើមវិញ ។ ក្រោយមក មន្ត្រីយោធាដែលបានចុះឈ្មោះទាំងអស់ ត្រូវបាននាំយកទៅសម្លាប់ចោលគ្មានសល់ ។ បន្ទាប់មក វ៉ាស៊ី បានពន្យល់ពីរបៀបដែលខ្មែរក្រហមធ្វើខ្នោះដៃនិងជើង ។ ចុងក្រោយ វ៉ាស៊ី បានធ្វើសេចក្តីសន្និដ្ឋានទៅលើជំពូកទាំងមូលដោយរៀបរាប់ថា ខ្មែរក្រហមបានបែងចែកសត្រូវជាពីរផ្នែកគឺ សត្រូវខាងក្នុង និងសត្រូវខាងក្រៅ ។ វ៉ាស៊ី បានសួរសិស្សថាតើមានស្គាល់មនុស្សនៅក្នុងប្រភេទទាំងពីរនេះដែរឬទេ ។

## ២. សំណួររបស់អ្នកចូលរួម

នៅចុងបញ្ចប់នៃការធ្វើបទបង្ហាញ វ៉ាស៊ី បានផ្តល់ឱកាសដល់អ្នកចូលរួមឲ្យលើកជាសំណួរផ្សេងៗ ។ បូលី និង ពៅដារ៉ា បានជួយក្នុងការឆ្លើយសំណួរ ។ សំណួរមួយចំនួនដែលអ្នកចូលរួមបានសួរមានដូចខាងក្រោមៈ

១. ហេតុអ្វីបានជាខ្មែរក្រហមកើតឡើង?

២. ខ្មែរក្រហមចង់បង្កើតសង្គមមួយដែលគ្មានភាពក្រីក្រ និងពុករលួយ ហើយជាសង្គមមួយដែលអាចឲ្យមនុស្សរស់នៅស្មើភាពគ្នា និងដោយក្តីរីករាយ ។ ហេតុអ្វីបានជា ប៉ុល ពត សម្លាប់មនុស្ស ប្រសិនបើខ្លួនមិនចង់ឲ្យប្រជាជនត្រូវគេជិះជាន់?

៣. តើនរណាជាអ្នកកាន់អំណាចនៅក្នុងអំឡុងពេលរបបខ្មែរក្រហម?

៤. តើរបបខ្មែរក្រហមនឹងកើតឡើងម្តងទៀតទេ?

៥. ឪពុកម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា ខ្មែរក្រហមបានផលិតអង្ករបានយ៉ាងច្រើន ប៉ុន្តែប្រជាជនបែរជាជួបគ្រោះអត់ឃ្លាននៅពេលនោះ ។ តើពួកគេបានយកអង្ករទាំងអស់នោះទៅណា? ហេតុអ្វីបានជាខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនហូបឲ្យបានគ្រប់គ្រាន់?

៦. ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់បញ្ញវន្ត បើមេដឹកនាំខ្មែរក្រហមមួយចំនួនសុទ្ធតែជាមនុស្សដែលមានការអប់រំ?

វ៉ាស៊ី បានឆ្លើយតបសំណួរទៅកាន់អ្នកចូលរួមក្នុងលក្ខណៈស្រពិចស្រពិល ។ គាត់បាននិយាយថា " យើងមិនចង់ឲ្យអំពើប្រល័យពូជសាសន៍កើតឡើងនៅលើទឹកដីរបស់ប្រទេសកម្ពុជាយើងម្តងទៀតទេ ។ "នេះជា

មូលហេតុដែលយើងនៅទីនេះជាមួយគ្នាថ្ងៃនេះ» ។ លោក ឌី លោក វ៉ាន់ថាន់ ជាមួយ លោក វ៉ាស៊ីបានឆ្លើយសំណួរផ្សេងៗទៀត ។

## ៣ ប្រតិកម្មរបស់អ្នកចូលរួម

កូនសិស្សភាគច្រើនបានបង្ហាញនូវភាពវិជ្ជមាន នៅពេលដែលបានសួរថាតើពួកគេបានលឺអីខ្លះអំពីខ្មែរក្រហម ។ ពួក គេបានលឺរឿងរ៉ាវនេះពីឪពុកម្តាយរបស់ពួកគេ និង បានរៀននៅក្នុងសាលា ។ នៅពេលនរណាម្នាក់បាន ឡើងសួរសំណួរ « តើគិតអ៊ីមុនគេនៅពេលអ្នកនិយាយពីរបបខ្មែរក្រហម? » សិស្សធំៗ ឆ្លើយថា ការសម្លាប់ បង្ខំធ្វើការហួសកម្លាំង បង្អត់អាហារ ការជម្លៀស និង ការបំបែកគ្រួសារ ។ គ្រូម្នាក់ បាននិយាយថា គាត់បានឆ្លងកាត់ដោយផ្ទាល់នៅក្នុងរបបដ៏លំបាកនេះ ។ ប៉ុន្តែគាត់បានចងចាំនូវរឿងរ៉ាវខ្លះៗ របស់គាត់តែ ប៉ុណ្ណោះ ប៉ុន្តែគាត់មិនអាចរំលឹកនូវទិដ្ឋភាពធំៗនៃរបបខ្មែរក្រហមបានទេ ។ ឧទាហរណ៍ គាត់មិនបានដឹងពី ចំនួនភូមិភាគក្នុងរបបកម្ពុជាប្រជាធិតេយ្យដូចដែលបានចេញក្នុងការប្រលងថ្នាក់វិទ្យាល័យ ភាពសាំញ៉ាំផ្នែក ប្រវត្តិសាស្ត្រសម្រាប់អ្នករស់រានមានជីវិត គឺមិនមានសារសំខាន់ដូចជាប្រវត្តិរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេ ប៉ុន្តែ ភាពសាំញ៉ាំប្រហែលជាជួយឆ្លើយនូវសំណួរច្រើនដូចជាសំណួរ « ហេតុអ្វី » ។ គ្រូក៏បានសង្កត់ធ្ងន់ថាវាមានសារសំខាន់ណាស់ដែលប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវបានចងក្រងជាឯកសារបានយ៉ាងល្អ ។ រសៀលថ្ងៃត្រង់គ្រូមការងារ បាន ធ្វើបទសម្ភាសជាមួយអ្នកភូមិ គ្រូបង្រៀន និង កូនសិស្សដើម្បីប្រមូលគំនិតរបស់ពួកគេទៅលើការបង្រៀន « ប្រវត្តិ សាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ។ ខាងក្រោមនេះ គឺជាការដកស្រង់បន្ថែមពីការធ្វើបទសម្ភាសៈ

ភឿ ស្រីនួន អាយុ ១៨ឆ្នាំ ជាសិស្សមកពីសាលា ហ៊ុនសែន អន្លង់ជ្រៃ ។ ឪពុកម្តាយរបស់ស្រី នួន ជាកសិករនៅភូមិត្រាំង វែង ឃុំប្រាំបីមុំ ស្រុកសង្កែ ។ នាងមានបងប្អូនបង្កើត ៥នាក់ ។ បន្ថែមទៅលើការសិក្សា របស់នាង នាងបានជួយឪពុកម្តាយរបស់នាងធ្វើស្រែចំការ និង ចិញ្ចឹមជ្រូក ។ ស្រីមុំបានយល់ច្រើនអំពីខ្មែរ ក្រហមបន្ទាប់ពីបានចូលរួមវេទិកាសាធារណៈ ។ នាងបានឃើញទស្សនាវដ្តី«ស្វែងរកការពិត» ប៉ុន្តែមិនបានយកចិត្ត ទុកដាក់ច្រើនពីសៀវភៅនេះទេ ។ នៅក្នុងសាលា ស្រីនួន ជាទូទៅសិក្សាពី សង្គ្រាមលោកលើកទី ២ និង របប លន់ នល់ប៉ុន្តែមិនបានរៀនច្រើនពីរបបខ្មែរក្រហម ។ មានពេលខ្លះឪពុកម្តាយនាងបាននិយាយពីបទពិសោធន៍រប ស់ពួកគេក្នុងរបបខ្មែរក្រហមឲ្យនាងស្តាប់ ។ នាងបានដឹងថាម្តាយរបស់នាងគឺជាប្រជាជនម្នាក់នៅក្នុងខេត្ត តាកែវ ហើយត្រូវបានជម្លៀសមកខេត្តកំពង់ស្ពឺអំឡុងពេលរបបខ្មែរក្រហម ហើយបានរស់នៅទីនេះចាប់តាំងពី ពេលនោះមក ។ ក្នុងរបបខ្មែរក្រហមម្តាយរបស់នាងត្រូវបានបង្ខំឲ្យរែកដីធ្វើទំនប់ ។ នៅពេលដែលបានសួរ

នាងថាតើនាងចង់រៀនពីរបបខ្មែរក្រហមទេ នាងនិយាយថា « ប្រសិនបើមានមនុស្សម្នាក់ប្រាប់ខ្ញុំ ខ្ញុំចង់ រៀន ។ ប្រសិនបើមិនមានការអប់រំពីប្រវត្តិសាស្ត្រនោះទេ ខ្ញុំក៏មិនខ្វល់ដែរ ក្នុងគំនិតរបស់ខ្ញុំ ពាក្យថារបបខ្មែរក្រហមមានន័យថា ការសម្លាប់ និង គ្មានការអភិវឌ្ឍន៍ ។ នាងផ្តល់យោបល់ថារបបខ្មែរក្រហមថាជាអំពើសាហាវឃោរឃៅ ។ នាងបាននិយាយថាវាពិតជាខុសគ្នាបើប្រៀបធៀបនិងសព្វថ្ងៃ ។ ឪពុករបស់នាងបានជម្រុញនាងឲ្យរៀនសូត្រដោយនិយាយថាគាត់គ្មានឱកាសបានរៀនសូត្រទេនៅពេលគាត់មានវ័យប៉ុននេះ ។ ឥឡូវអ្នកមានសាលាក្បែរផ្ទះ ។ ផ្ទះរបស់ស្រីនួនស្ថិតនៅក្បែរផ្ទះរបស់បុរសម្នាក់ដែលជាអតីតកម្មាភិបាលខ្មែរ ក្រហម ។ ឪពុករបស់នាងបាននិយាយថាបុរសម្នាក់នោះជាមនុស្សសាហាវម្នាក់ក្នុងរបបខ្មែរក្រហម ។ បុរសម្នាក់នោះបានឈឺ ហើយស្លាប់ដោយសារជំងឺអស់រយៈពេល ពីរ បីឆ្នាំទៅហើយ ។ ស្រីនួនមិនមានអារម្មណ៍ ស្អប់ខ្ពើមចំពោះកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមទេ ។ នាងបាននិយាយថា « គាត់បានធ្វើអំពើអាក្រក់ច្រើន ប៉ុន្តែកូនរបស់គាត់មិនបានប្រព្រឹត្តនូវកំហុសផ្សេងៗដូចជាឪពុករបស់គេបានធ្វើនោះទេ» ។ ម្យ៉ាងវិញទៀត កម្មាភិបាលខ្មែរក្រហមបានប្រព្រឹត្តបទឧក្រិដ្ឋកម្មទាំងអស់នោះពីព្រោះតែគាត់ត្រូវបានគេបញ្ជាឲ្យធ្វើទេ» ។ស្រីនួនបាននិយាយថានាងរាប់អានធម្មតាជាមួយកូនរបស់អតីតកម្មាភិបាលខ្មែរក្រហម ។ បើទោះបីជាកម្មាភិបាលខ្មែរក្រហមបានសម្លាប់សាច់ញាតិបងប្អូនរបស់នាងក៏ដោយនាងបាននិយាយថានាងនៅតែនិយាយជាមួយកូនរបស់គាត់ដូចធម្មតា ប៉ុន្តែផ្ទុយទៅវិញនាងមិនអាចនិយាយជាមួយនឹងជនដៃដល់ទេ ។

២. ឃឹម វ៉ន ជាគ្រូបង្រៀនកំរិតអនុវិទ្យាល័យ ។ វ៉ន រស់នៅភូមិថ្មី ឃុំ រុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ វ៉នចាប់អារម្មណ៍បង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមដោយសារមូលហេតុសំខាន់ពីរ ។

ទីមួយ ដោយសារតែគាត់គឺជាគ្រូប្រវត្តិសាស្ត្រ

ទីពីរ គាត់ចង់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ដូច្នេះក្មេងជំនាន់ក្រោយអាចដឹងដើម្បីជៀសផុតពីការធ្វើកំហុសដូចគ្នា ដូចកាលជំនាន់របស់គាត់បានធ្វើ ។

គាត់បាននិយាយថានៅពេលដែលសិស្សបានក្លាយទៅជាអ្នកដឹកនាំសង្គមមួយ ហើយបានដឹងរឿងទាំងអស់នេះនឹង ជួយការពារពួកគេពីការដើរទៅរកវាសនាដូចគ្នា ។ វ៉ន គិតថាប្រវត្តិសាស្ត្រខ្មែរក្រហមគឺខុសពីប្រវត្តិសាស្ត្រដ៏ទៃទៀត ។ គាត់ចង់ឲ្យកូនសិស្សបានដឹងពីប្រវត្តិសាស្ត្រទាំងមូលក្នុងរបបខ្មែរក្រហម និងការដួលរលំនៃរបបខ្មែរក្រហមនៅក្នុងមេរៀនជំពូកទី ១១ ។ គាត់បាននិយាយថា គាត់និងប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីអប់រំកូនសិស្សពីព្រោះអ្វីដែលខ្មែរក្រហមបានធ្វើវាប្រឆាំងនឹងទស្សនៈរបស់ប្រជាជន ។ មកទល់សព្វថ្ងៃ គាត់នៅតែរំលឹកពីបទពិសោធន៍របស់គាត់ក្នុងរបបខ្មែរក្រហម ។

ជាពិសេសគាត់បាននិយាយពីការលំបាករបស់ម្តាយគាត់ដែលបាន ជួបប្រទះអំឡុងពេលនោះ ។ «ម្តាយរបស់ខ្ញុំបានក្រោកពីព្រលឹមរាល់ថ្ងៃ ហើយបានដើរទៅកាន់ភូមិផ្សេងទៀត ដែលមានចំងាយប្រហែលជា

២០គីឡូម៉ែត្រ ។ ម្តាយរបស់គាត់ត្រូវបានស្នើរទៅភ្ជួរដែលការងារនោះគឺជាកិច្ចការ របស់មនុស្សប្រុស ។ គាត់ត្រូវបានផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀតជារៀងរាល់កន្ទះខែម្តង ។ ការធ្វើ ដំណើរជាទូទៅបាន ចាប់ផ្តើមនៅពាក់កណ្តាលយប់ដើម្បីសំចៃពេលវេលា ។ បងប្អូនរបស់ខ្ញុំត្រូវបានគេបំបែក ចេញពីគ្នា ។ « ម្តាយរបស់ គាត់បានយំរាល់ពេលដែលគាត់រំលឹកពីបទពិសោធន៍របស់គាត់នៅក្នុងរបបនោះ » ។ វ៉ន មានការ សោកស្តាយដែលរបបបែបនេះបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ វ៉ន បាននិយាយថា គាត់មិនអាចអត់អោន ឲ្យមេដឹកនាំជាន់ខ្ពស់បានទេ ពីព្រោះបទឧក្រិដ្ឋរបស់គេសូម្បីតែសហគមជាតិនិង អន្តរជាតិក៏មិនអាចទទួលយកបានដែរ ។ ប៉ុន្តែ ទោះបីជាយ៉ាងណា គាត់បាននិយាយថាគាត់អាចអត់អោនឲ្យ កម្មាភិបាលថ្នាក់ក្រោមដែលធ្វើតាមតែបញ្ជារប ស់គេ ។ វ៉ន ជឿជាក់ថាការបង្រៀនពី « ប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិតេយ្យ គឺពិតជាសំខាន់» ។ ក្មេងៗចាំបាច់ត្រូវតែទទួលបាននូវការអប់រំមិនឲ្យគិតពីការសងសឹក ប៉ុន្តែឲ្យមានការអាណិតអាសូរចំពោះគ្នាទៅវិញទៅមក ។ គាត់ជឿថាការបង្រៀននិងនាំទៅដល់វិសាលភាព នៃការផ្សះផ្សារជាតិ និង ព្យាបាលរបួសផ្លូវចិត្ត ។ គាត់បាននិយាយថាយើងចាំបាច់ត្រូវតែយល់ជាមុនសិនមុន ពេលយើងអាចបន្តទៅរកការផ្សះផ្សារ ។ ការរើសអើ ងគឺនៅតែកើតមាននៅក្នុងភូមិរបស់គាត់ ។ យោងទៅលើ បទពិសោធន៍របស់គាត់នៅក្នុងការបង្រៀនសិស្សអំពី ប្រវត្តិសាស្ត្រខ្មែរក្រហម កូនសិស្សសប្បាយរីករាយ និង ចាប់អារម្មណ៍ ប៉ុន្តែពួកគេមានការប្រៀបធៀបច្រើន ពីអំពើព្រៃផ្សៃដែលកើតឡើងនៅប្រទេសដទៃទៀត ។ កូនសិស្សជឿជាក់ថា ការសម្លាប់ និង ការធ្វើទារុណកម្មនៅក្នុង ប្រទេសកម្ពុជាគឺមានលក្ខណៈឃោរឃៅ ជាងប្រទេសដទៃ ។ កូនសិស្សម្នាក់ក្នុងចំណោមកូនសិស្សទាំងអស់របស់គា ត់បាននិយាយថា « នៅពេលអនាគត ប្រសិនបើខ្ញុំក្លាយទៅជាអ្នកដឹកនាំ ខ្ញុំនិងជម្រុញឲ្យមានការបង្រៀនប្រវត្តិសាស្ត្រពិត» ។ ខ្ញុំនិងមិនដើរតាមខ្មែរ ក្រហមទេ ។

៣. ផែន សាន់ អាយុ ៦៤ ឆ្នាំ ជាអ្នកភូមិកំពុងរស់នៅភូមិ អូរអង្គ ឃុំអម្លាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ៖ នៅ ក្នុងរបបខ្មែរក្រហម គាត់រស់នៅក្នុងកងចល័តផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀត ។ គាត់ត្រូវបានគេរៀបចំ ឲ្យលើទំនប់ ដីប្រឡាយ ។ គាត់គឺជាអតីតគ្រូបង្រៀនអនុវិទ្យាល័យអស់រយៈពេលជិត ២៨ឆ្នាំហើយ ហើយ គាត់ទើបតែចូលនិវត្តន៍បាន ៤ឆ្នាំ ។ នៅពេលដែលគាត់នៅជាគ្រូបង្រៀន គាត់តែងតែបានប្រាប់កូន សិស្ស និង កូនៗរបស់គាត់អំពីជីវិតនៅក្នុងរបបខ្មែរក្រហម និង បទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ ។ គាត់ចង់អោ យកូនៗរបស់គាត់ និងអ្នកដ៏ទៃបានដឹងពីការឈឺចាប់របស់ប្រជាជនកម្ពុជានាពេលនោះ និង ដឹងនូវអ្វីដែលខ្មែរ ក្រហមបានធ្វើមកលើប្រជាជន ។
វាជារឿងសំខាន់ណាស់សម្រាប់ក្មេងជំនាន់ក្រោយដើម្បីដឹងនូវប្រវត្តិសាស្ត្រនេះ
ដើម្បីឲ្យពួកគេចេះគិតពិចារណាអំពីការឈឺចាប់របស់ឪពុកម្តាយ ។ និយាយអំពីរបបខ្មែរក្រហម គាត់បានរំលឹ

កពីការសម្លាប់ ការធ្វើការលំបាក និង អាហារមិនគ្រប់គ្រាន់ ។ នៅពេលដែលគាត់កំពុងឡើងយកទឹកត្នោត គាត់បានឃើញខ្មែរក្រហមបណ្តើរមនុស្សទាំងខ្សែរទៅកាន់កន្លែងសម្លាប់ ។ គាត់តែងតែរៀបរាប់ពីប្រវត្តិរបស់គាត់ក្នុងរបបខ្មែរក្រហមឲ្យកូនចៅរបស់គាត់ស្តាប់បន្ទាប់ពីទទួលទានអាហារពេលយប់ក្នុងពេលដែលគ្រួសារនិយាយជជែកគ្នាលេង ។ គាត់មិនហ៊ានធានាថាតើកូនៗរបស់គាត់បានជឿនូវអ្វីដែលគាត់បាននិយាយប្រាប់ពួកគេដែរឬទេ ។ ប៉ុន្តែក៏មិនមានកូនណាម្នាក់និយាយថា « ខ្ញុំមិនជឿគាត់ទេ » ។ ផ្ទុយទៅវិញកូនៗរបស់គាត់មានអារម្មណ៍ អាណិតអាសូរឪពុកម្តាយ និង ប្រជាជនដែលទទួលបាននូវបទពិសោធន៍ដ៏ពិបាកបែបនេះ ។ គាត់ជឿជាក់ថារបបខ្មែរក្រហមគួរតែត្រូវបានបង្រៀននៅក្នុងសាលាដើម្បីចងក្រងការចងចាំដូច្នេះអំពើឃោរឃៅ និង មិនអាចកើតឡើង ជាលើកទីពីរទៀត ។ សម្រាប់គាត់ ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនិងនាំមកនូវការអត់អោនដោយគ្មានការបែ ងចែក ។ គាត់រស់នៅគ្រប់ទីកន្លែងជាមួយអតីតកម្មាភិបាលខ្មែរក្រហម ។ ទោះបីជាយ៉ាងណាក៏ដោយ ការ រស់នៅរបស់គាត់គឺធម្មតាពីព្រោះប្រធានធំរបស់ខ្មែរក្រហមរស់នៅក្នុងភូមិបានស្លាប់យូរណាស់មកហើយ ។ គាត់មិន មានការរើសអើងជាមួយនិងកូនរបស់ជនដៃដល់ទេ ហើយពួកគេលេងជាមួយគ្នាដូចធម្មតា ។

**តារាងៈ បញ្ជីឈ្មោះអ្នកត្រូវបានសម្ភាស**

១. គៀន ស្រីនួន ស្រី សិស្ស ភូមិត្រាំវែង ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
២. យាង យុធា ប្រុស សិស្ស ភូមិអន្លង់ជ្រៃ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
៣. ដៃ វីន ប្រុស សិស្ស ភូមិចំបកធំ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ៤. កែវសុខម ស្រី សិស្ស ភូមិអូរអង្គុំ ឃុំអម្លាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ៥. ដែន សាន់ ប្រុស ឪពុក ភូមិអូរអង្គុំ ឃុំអម្លាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
៦. ទុយ សាវរី ស្រី សិស្ស ភូមិស្នួល ឃុំអម្លាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ៧. ឃឹម វិន ប្រុស គ្រូ ភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ៨. អឺ រ៉ា ប្រុស ឪពុក ភូមិអូរអង្គុំ ឃុំអម្លាមង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

**ឧបសគ្គ**

ការអញ្ជើញអ្នកចូលរួមឲ្យមកចូលរួមវេទិកា គឺជាជំហានដំបូងដ៏សំខាន់ដើម្បីធានាពីភាពជោគជ័យនៃវេទិកា ។ អ្នកចូលរួមចាំបាច់ត្រូវតែទទួលដំណឹងឲ្យបានច្បាស់លាស់ពីរ បីថ្ងៃមុនពេលការចាប់ផ្តើមនូវវេទិកា ។ ពួកគេចាំបាច់ត្រូវតែមានការលើកទឹកចិត្ត និង មានលទ្ធិភាពដើម្បីដឹងពីតំលៃនៃការចូលរួមនៅក្នុងវេទិកា ។ ដោយ សារតែក្រុមការងារ មិនបាននៅទីនោះដោយផ្ទាល់ អ្នកផ្តល់ដំណឹងដ៏សំខាន់គឺជាគ្រូថ្នាក់ខេត្ត និង

អាជ្ញាធរដែនដី ដែលជួយយើង អញ្ជើញអ្នកភូមិ កូនចៅរបស់ពួកគេកំពុងរៀននៅសាលា ឬអ្នកភូមិទូទៅ ។ នៅក្នុងវេទិកាដំបូង នេះ នាយកសាលា និង គ្រូថ្នាក់ខេត្តមានលទ្ធិភាពអញ្ជើញអ្នកភូមិបានតែ ប្រាំមួយនាក់ ក្រៅពីនោះគឺសុទ្ធតែ កូនសិស្ស ដែលមករៀនគួរអំឡុងពេលវិស្សមកាល ។ ដើម្បីដោះស្រាយឧបសគ្គនេះ សាមាជិកក្រុមការងារគួរ តែទាក់ទងជាមួយគ្រូថ្នាក់ខេត្ត និង ជាពិសេសជាមួយនិងអាជ្ញាធរដែនដីដែលមានទំនាក់ទំនងជាមួយយើងក្នុងការ ជួយអញ្ជើញអ្នកភូមិដែលអ្នកទាំងនោះគឺត្រូវបានចាត់ទុកថាជាទិសដៅរបស់គម្រោង ។ ក្រុមការងារត្រូវតែពន្យល់ អ្នកផ្តល់ដំណឹងទាំងពីរនាក់ឲ្យបានច្បាស់អំពីគោលបំណង និង វត្ថុបំណងនៃវេទិការសាធារណៈ ។ អ្នកភូមិខ្លួនឯងក៏ត្រូវតែឃើញពីតំលៃនៃការចូលរួមនៅក្នុងវេទិការសាធារណៈ ជាជាងគ្រាន់តែឲ្យគាត់មកចូល រួម ។ វេទិការសាធារណៈគឺជាការអប់រំអំពើប្រល័យពូជសាសន៍ក្រៅផ្លូវការ ដូច្នេះចំនួនអ្នកចូលរួមគួរតែរៀបចំ ពី ៧០ ដល់ ២០០នាក់ ។ វេទិការគួរតែរៀបចំនៅកន្លែងផ្សេងក្រៅពីសាលារៀន ។

**ការធ្វើបទបង្ហាញ:**

ការធ្វើបទបង្ហាញពីសៀវភៅសិក្សាគួរតែត្រូវបានរៀបចំឲ្យបានល្អជាជាងការបង្រៀនប្រវត្តិសាស្ត្រដោយជ្រើសរើសដោយចៃដន្យក្នុងចំណោមមេរៀនទាំង ១១ជំពូកនៅក្នុងសៀវភៅសិក្សា ។ ក្រុមការងារត្រូវតែស្វែងយល់ឲ្យបានច្បាស់លាស់នូវអ្វីដែលខ្លួនចង់សំរេចបាននៅចុងបញ្ចប់នៃវេទិកា ។ វិធានបទសម្រាប់ធ្វើបទបង្ហាញគួរតែបានជ្រើសរើសដោយផ្អែកទៅលើទីតាំង ។ ឧទាហរណ៍ បទបង្ហាញទៅលើ « ការបន្សុតនៅក្នុងភូមិភាគបូព៌ា » គួរតែធ្វើនៅក្នុងខេត្តព្រៃវែង ។ អ្នកធ្វើបទបង្ហាញចាំបាច់ត្រូវធ្វើតាមដំណាក់កាលៗនៃការធ្វើបទបង្ហាញដោយប្រកាន់ភ្ជាប់នូវការណែនាំនៅក្នុងសៀវភៅណែនាំគ្រូបង្រៀន ដែលបង្កើតឲ្យមានការត្រិះរិះពិចារណា ។ ជាងនេះទៅទៀតដើម្បីជម្រុញនូវសកម្មភាពសន្ទនា អ្នកចូលរួមគួរតែមានឱកាសបន្ថែមក្នុងការនិយាយ និង ចូលរួមនៅក្នុងការអាន និង ការពិភាក្សា ។ កិច្ចសន្ទនាក្នុងចំណោមអ្នកភូមិ គ្រូ និង ក្មេងៗនិងផ្តល់ឲ្យមានការពិភាក្សាបន្ថែមនៅផ្ទះបន្ទាប់ពីបញ្ចប់វេទិកា ។ នៅក្នុងន័យនេះ យើងអាចចែកអ្នកចូលរួមជាក្រុម និង ឲ្យអាននូវផ្នែកៗនៃមេរៀនធ្វើដូច្នេះពួកគេមានមូលដ្ឋានសម្រាប់ធ្វើការពិភាក្សា ។

ដើម្បីដោះស្រាយជាមួយឧបសគ្គនេះ ក្រុម ការងារដែលនិងធ្វើបទបង្ហាញ ឬក៏បង្រៀនត្រូវតែរៀបចំមេរៀនគំរូជាមុន និង នាំយកសម្ភារសម្រាប់បង្រៀនពី ការិយាល័យឲ្យបានគ្រប់គ្រាន់ ។ វាពិតជាមានសារសំខាន់ណាស់ដើម្បីធានាថាកម្មវិធីសម្រាប់វេទិកាសាធារណៈស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ គឺយកមកអនុវត្តន៍ រៀបចំបានល្អ និង មានការសំរបសំរួលបានល្អ ។

**លទ្ធិផល និង ការសង្កេតការណ៍ទូរទៅ**

វេទិកាសាធារណៈស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងជាមួយអ្នកភូមិនៅក្នុងសហគមនានាដើម្បីមកចូលរួមក្នុងដំណើរការអប់រំអំពើប្រល័យពូជសាសន៍ប្រកបដោយគរុកោសល្យ និង សាមញ្ញ ។ វេទិការនេះនាំមកនូវការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំអំពើប្រល័យពូជសាសន៍ទៅដល់សហគមន៍ ដោយជម្រុញឲ្យមានការសន្ទនារវាងអ្នកភូមិ មនុស្សចាស់ កូនសិស្ស និង គ្រូបង្រៀន ពីព្រោះអ្នកទាំងអស់នេះគឺជាសមាជិកចូលរួមដ៏សំខាន់នៅ ក្នុងដំណើរការអប់រំ ។ យោងទៅលើបទសម្ភាសន៍ដែលបានធ្វើជាមួយនិងអ្នកភូមិ អ្នកទាំងអស់នោះចង់ឲ្យរឿងរ៉ាវរបស់គេបានលឺទាំងនៅក្នុង និង ក្រៅសាលារៀនដោយផ្តល់នូវបទពិសោធនរបស់ពួកគេតាមរយៈការស្តាប់ និង រៀនដើម្បីឲ្យមានការទទួលស្គាល់ត្រឹមត្រូវតាមច្បាប់ ។ ទោះបីការធ្វើវេទិការជាលើកដំបូងនៅខេត្តកំពង់ស្ពឺមានចំណុចខ្សោយមួយចំនួន វេទិការទាំងនេះគឺជាជំហានដ៏រ៉ឹងមាំឆ្ពោះទៅរកការចែករំលែកការរៀនសូត្រពីរបបខ្មែរក្រហម និង ការឈឺចាប់ដែលមិនអាចបំភ្លេចបានសម្រាប់ប្រជាជនដែលបានជួបប្រទះ ។

**សមាជិកគម្រោង**

**ឌី ខាំបូលី**

**ដេងពង្សរ៉ាស៊ី**

**ប្រាក់កែវដារ៉ា**

**លី សុខចំរើន**